**ព្រះរាជាណាចក្រកម្ពុជា**

**ជាតិ សាសនា ព្រះមហាក្សត្រ**

**ក្រសួងសង្គមកិច្ច ការងារ បណ្តុះបណ្តាលវិជ្ជាជីវៈ**
**និង យុវនីតិសម្បទា**

លេខ : ០៩៦ សកបយ

រាជធានីភ្នំពេញ ថ្ងៃទី ១២ ខែ មីនា ឆ្នាំ២០០៣

# ប្រកាស
## ស្តីពី
## ការតែងតាំងក្រុមប្រឹក្សាអាជ្ញាកណ្តាល

**រដ្ឋមន្ត្រីក្រសួងសង្គមកិច្ច ការងារ បណ្តុះបណ្តាលវិជ្ជាជីវៈ និងយុវនីតិសម្បទា**

-បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា

-បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/១១៩៨/៧២ ចុះថ្ងៃទី ៣០ ខែ វិច្ឆិកា ឆ្នាំ ១៩៩៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា

-បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែកក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសអោយប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី

-បានឃើញព្រះរាជក្រមលេខ ជស/រកម/០៣៩៧/០១ ចុះថ្ងៃទី ១៣ ខែ មីនា ឆ្នាំ១៩៩៧ ដែលប្រកាសអោយប្រើច្បាប់ស្តីពីការងារ

-បានឃើញព្រះរាជក្រមលេខ នស/រកម/០៦៩៩/០៦ ចុះថ្ងៃទី ១៧ ខែ មិថុនា ឆ្នាំ១៩៩៩ ដែលប្រកាសអោយប្រើច្បាប់ស្តីពីការបង្កើតក្រសួងសង្គមកិច្ច ការងារ បណ្តុះបណ្តាលវិជ្ជាជីវៈ និងយុវនីតិសម្បទា

-បានឃើញអនុក្រឹត្យលេខ ៨៧ អនក្រ/បក ចុះថ្ងៃទី ០៤ ខែ តុលា ឆ្នាំ ១៩៩៩ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅរបស់ក្រសួងសង្គមកិច្ច ការងារ បណ្តុះបណ្តាលវិជ្ជាជីវៈ និងយុវនីតិសម្បទា

-បានឃើញប្រកាសលេខ ១៤១ សកបយ ចុះថ្ងៃទី ០៧ ខែ មិថុនា ឆ្នាំ ២០០២ ស្តីពីការបង្កើតគណៈកម្មការប្រឹក្សាគម្រោងដោះស្រាយវិវាទការងារនៅកម្ពុជា

-បានឃើញប្រកាសលេខ ៣៣៨ សកបយ ចុះថ្ងៃទី ១១ ខែ ធ្នូ ឆ្នាំ ២០០២ ស្តីពីក្រុមប្រឹក្សាអាជ្ញាកណ្តាល

-បានឃើញលិខិត ចុះថ្ងៃទី ២៨ ខែ កុម្ភៈ ឆ្នាំ ២០០៣ របស់ប្រធានទីប្រឹក្សាបច្ចេកទេសនៃគម្រោងដោះស្រាយវិវាទការងារនៅកម្ពុជា ស្តីពីសំណើសុំតែងតាំងសមាជិកក្រុមប្រឹក្សាអាជ្ញាកណ្តាល

## ស ម្រេ ច

**ប្រការ១.-** តែងតាំងក្រុមប្រឹក្សាអាជ្ញាកណ្តាល ដែលមានសមាសភាពដូចខាងក្រោមនេះ ៖

**I – សមាជិកដែលស្នើឡើងដោយក្រសួងសង្គមកិច្ច ការងារ បណ្តុះបណ្តាលវិជ្ជាជីវៈ និងយុវនីតិសម្បទា**

១-លោក អាំង អេងថុង

២-លោកជំទាវ គឹម សេត្ថារី

៣-លោក គឹម យាទយ៉ារិទ្ធ

៤-លោក គង់ ផាល័ក្ខណ៍

៥-លោក RENDALL Matthew

៦-លោក សុខ ម៉ាធឿន

៧-លោក សា សាវណ្ណ

II- សមាជិកដែលស្នើឡើងដោយសមាគមនិយោជក

១-លោក Gui Anvanith

២-លោក ហេង ជី

៣-លោក មារ សំបូរណា

៤-លោក អ៊ុក រី

៥-លោក វង់ ជីវ

៦-អ្នកស្រី យូ ស៊ុនធី

៧-លោក KIM Leong Lee

III- សមាជិកដែលស្នើឡើងដោយសហជីព កម្មករ និយោជិត (សហព័ន្ធសហជីព)

១-លោក អន ណន

២-លោក កុយ នាម

៣-លោក លីវ សូវណ្ណា

៤-អ្នកស្រី ស៊ីន គីមស៊ាន

៥-លោក សុង វ៉ាន់ស៊ិន

៦-លោក ទូន ស៊ីផាន់

៧-លោក វង្ស វណ្ណា

**ប្រការ២:-** យោងមាត្រា ៣១២ នៃច្បាប់ស្តីពីការងារ ក្រុមប្រឹក្សាអាជ្ញាកណ្តាលមានភារកិច្ចដូចតទៅ :

ក្រុមប្រឹក្សាអាជ្ញាកណ្តាល គ្មានភារកិច្ចពិនិត្យ បញ្ហាដទៃក្រៅពីបញ្ហាដែលមានបញ្ជាក់ក្នុងកំណត់ហេតុ មិនព្រមសះជា ឬបញ្ហាដែលកើតក្រោយការធ្វើកំណត់ហេតុជាផលវិបាកផ្ទាល់នៃការវិវាទនោះតែប៉ុណ្ណោះ ។

ក្រុមប្រឹក្សានេះ ដោះស្រាយជាផ្លូវច្បាប់ចំពោះការវិវាទដែលទាក់ទងនិងការបកស្រាយ និងការអនុវត្តន៍បញ្ញត្តិច្បាប់ ឬ អនុសញ្ញារួមណាមួយ ។ ក្រុមប្រឹក្សានេះ ដោះស្រាយដោយសមធម៌ ចំពោះការវិវាទឯទៀតទាំងអស់ ។

ក្រុមប្រឹក្សាអាជ្ញាកណ្តាលមានអំណាចធំទូលាយ ដើម្បីស៊ើបអំពីស្ថានភាពសេដ្ឋកិច្ច នៃសហគ្រាស និងស្ថានភាពខាង សង្គមកិច្ច នៃកម្មករ និយោជិត ដែលជាសាមីខ្លួនក្នុងការវិវាទ ។ ៦

ក្រុមប្រឹក្សានេះ មានអំណាចអង្កេតគ្រប់បែបយ៉ាង នៅទីកន្លែងសហគ្រាស ឬអង្គការវិជ្ជាជីវៈផ្សេងៗ ព្រមទាំងមានអំណាចចាត់ឱ្យភាគីជូនឯកសារ ឬពត៌មានខាងសេដ្ឋកិច្ច គណនេយ្យ ស្ថិតិ ហិរញ្ញវត្ថុ ឬរដ្ឋបាល ដែលមានប្រយោជន៍ ក្នុងការបំពេញបេសកកម្មរបស់ខ្លួន ។ ក្រុមប្រឹក្សានេះ អាចសុំអ្នកជំនាញការជួយបានទៀតផង ។

សមាជិកនៃក្រុមប្រឹក្សាអាជ្ញាកណ្តាល ត្រូវលាក់អាថ៌កំបាំងវិជ្ជាជីវៈ ចំពោះពត៌មាន និងឯកសារទាំងឡាយ ដែលគេបានជូនមកឱ្យខ្លួនពិនិត្យ និងចំពោះហេតុការណ៍ទាំងអស់ដែលខ្លួនបានដឹង ក្នុងការបំពេញបេសកកម្មរបស់ខ្លួន ។

ការប្រជុំនៃក្រុមប្រឹក្សាអាជ្ញាកណ្តាល ត្រូវប្រព្រឹត្តទៅដោយបិទទ្វារ ។

**ប្រការ៣:-** កិច្ចដំណើរការ អំណាចយុត្តាធិការ ការចេញសេចក្តីបង្គាប់របស់ក្រុមប្រឹក្សាអាជ្ញាកណ្តាល ត្រូវអនុវត្តតាមបទបញ្ញត្តិនៃប្រកាសលេខ ៣៣៨ សកបយ ចុះថ្ងៃទី ១១ ខែ ធ្នូ ឆ្នាំ ២០០២ ព្រមទាំងវិធាននៃនីតិវិធីដែលជាឧបសម្ព័ន្ធនៃប្រកាសលេខ ៣៣៨ នេះផង ។

**ប្រការ៤:-** សមាជិកនៃក្រុមប្រឹក្សាអាជ្ញាកណ្តាលមានអាណត្តិមួយឆ្នាំ ដោយគិតចាប់ពីថ្ងៃទី ០១ ខែ ឧសភា ឆ្នាំ ២០០៣ ។

**ប្រការ៥:-** ប្រកាសនេះមានប្រសិទ្ធិភាពអនុវត្តចាប់ពីថ្ងៃចុះហត្ថលេខាតទៅ ។

អ៊ិត សំហេង

**ចម្លងជូន:**
- -ក្រសួងព្រះបរមរាជវាំង
- -អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- -អគ្គលេខាធិការដ្ឋានរដ្ឋសភា
- -ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី
- -ទីស្តីការគណៈរដ្ឋមន្ត្រី
- -គ្រប់ក្រសួងពាក់ព័ន្ធ "ដើម្បីជ្រាប"
- -អគ្គនាយកដ្ឋានកិច្ចការរដ្ឋបាល និងហិរញ្ញវត្ថុ នៃក្រសួងសង្គមកិច្ច ការងារ បណ្តុះបណ្តាលវិជ្ជាជីវៈ និងយុវនីតិសម្បទា "ដើម្បីអនុវត្ត និងផ្សព្វផ្សាយ"
- -អគ្គនាយកដ្ឋានការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ នៃក្រសួងសង្គមកិច្ច ការងារ បណ្តុះបណ្តាលវិជ្ជាជីវៈ និងយុវនីតិសម្បទា "ដើម្បីផ្សព្វផ្សាយ និងអនុវត្ត"
- -គ្រប់មន្ទីរសង្គមកិច្ច ការងារ បណ្តុះបណ្តាលវិជ្ជាជីវៈ និងយុវនីតិសម្បទា ខេត្ត-ក្រុង "ដើម្បីផ្សព្វផ្សាយ និងអនុវត្ត"
- -គ្រប់សមាគមនិយោជក "ដើម្បីជ្រាប"
- -គ្រប់សហព័ន្ធសហជីព "ដើម្បីជ្រាប"
- -គ្រប់បណ្តាញវិទ្យុ និងទូរទស្សន៍ "ដើម្បីជួយផ្សព្វផ្សាយ"
- -រាជកិច្ច
- -ឯកសារ-កាលប្បវត្តិ